មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីថ្លែងការណ៍

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដែលបង្ហាញពីរបកគំហើញសំខាន់ៗពីការសង្កេតសវនាការរបស់ខ្លួននៅសាលាឧទ្ធរណ៍ទាំងបួន នៅឆ្នាំ២០២៣

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២៤

ថ្ងៃនេះ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក ចេញផ្សាយរបាយការណ៍ប្រចាំឆ្នាំស្តីពី *"សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា៖ ការសង្កេតសវនាការនៅឆ្នាំ២០២៣"* ដែលធ្វើឡើងចាប់ពីថ្ងៃទី១ ខែមករា ដល់ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។ របាយការណ៍នេះ វិភាគលើទិន្នន័យដែលប្រមូលបានតាមរយៈការសង្កេតសវនាការប្រចាំថ្ងៃលើសំណុំរឿងព្រហ្មទណ្ឌចំនួន ៧៧២ ដោយមិនបានកំណត់ជាក់លាក់លើសំណុំរឿងណាមួយ ដែលពាក់ព័ន្ធនឹងជនជាប់ចោទចំនួន ១១១៨ នាក់ នៅសាលាឧទ្ធរណ៍**ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ** ដោយបានប្រើប្រាស់តារាងសង្កេតការណ៍សវនាការ ដែលបានរៀបចំយ៉ាងច្បាស់លាស់ ក្នុងគោលបំណងពិនិត្យនូវវិសាលភាពនៃបទដ្ឋានជាតិ និងអន្តរជាតិ ទាក់ទិននឹងការអនុវត្តសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

របាយការណ៍នេះរកឃើញថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមួយចំនួនត្រូវបានធានានៅចំពោះមុខសាលាឧទ្ធរណ៍ទាំងបួនដូចជា៖ សិទ្ធិក្នុងការជួបនិយាយជាមួយមេធាវីមុនការជំនុំជម្រះ សិទ្ធិមានពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដើម្បីរៀបចំការពារក្តី និងសិទ្ធិទទួលបានសេចក្តីសម្រេចជាសាធារណៈ។ គួរឱ្យសាទរ សិទ្ធិជាមូលដ្ឋានក្នុងការមានវត្តមាននៅពេលសវនាការត្រូវបានតុលាការគោលដៅចំនួនបី (**ភ្នំពេញ បាត់ដំបង** និង**ព្រះសីហនុ**) គោរពអនុលោមតាម។ សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលក៏ត្រូវបានតុលាការចំនួនបី (**បាត់ដំបង ត្បូងឃ្មុំ** និង**ព្រះសីហនុ**) គោរពផងដែរ ហើយសម្រាប់សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈក៏ត្រូវបានតុលាការចំនួនពីរ (**ភ្នំពេញ** និង**ត្បូងឃ្មុំ**) ធានាផងដែរ។

សាលាឧទ្ធរណ៍**ព្រះសីហនុ** បានបង្ហាញពីវឌ្ឍនភាពល្អប្រសើរដោយគោរពបាននូវសិទ្ធិសំខាន់ៗនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន ៦ ក្នុងចំណោមសិទ្ធិទទួលបានជំនុំជម្រះដោយយុត្តិធម៌ដែលត្រូវបានសង្កេតចំនួន ១៤ ហើយបើធៀបនឹងឆ្នាំ២០២២ ត្រូវបានគោរពត្រឹមតែសិទ្ធិចំនួន ៤ ប៉ុណ្ណោះ។ តុលាការព្រះសីហនុបានគោរពសិទ្ធិមានមេធាវី សិទ្ធិមានវត្តមាននៅពេលសវនាការ និងសិទ្ធិទទួលបានការសន្មតទុកជាមុនថាគ្មានទោសក្នុងអំឡុងពេលធ្វើរបាយការណ៍នេះជាលើកដំបូងចាប់តាំងពី ម.ស.ម.ក បានចាប់ផ្តើមសង្កេតសវនាការសំណុំរឿង

ព្រហ្មទណ្ឌនៅតុលាការនេះ។ សាលាឧទ្ធរណ៍**ភ្នំពេញ** បានគោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈយ៉ាងខ្ជាប់ខ្ជួននៅឆ្នាំ២០២៣។ ទោះជាសាលាឧទ្ធរណ៍ភ្នំពេញបានគោរពនូវសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ចំនួន ៤ ក្នុងចំណោមចំនួន ១៤ យ៉ាងណាក្តី នេះជាការខិតខំ និងបង្ហាញឱ្យឃើញពីការកែលម្អបើប្រៀបធៀបនឹងឆ្នាំ២០២២ ដែលតួលេខនេះមានតែចំនួន ៣ ប៉ុណ្ណោះ។

ផ្ទុយទៅវិញ សាលាឧទ្ធរណ៍**បាត់ដំបង**នៅមិនទាន់គោរពសិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈបានពេញលេញនៅឡើយទេ ថ្វីបើសិទ្ធិនេះត្រូវបានតុលាការនេះគោរពនៅឆ្នាំ២០២២ក៏ដោយ ដូច្នេះ តួលេខនៃការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗមានការថយចុះបន្តិចពីចំនួន ៥ មកនៅត្រឹម ៤ ក្នុងចំណោមចំនួន ១៤។ រីឯសាលាឧទ្ធរណ៍**ត្បូងឃ្មុំ**ក៏ត្រូវបានសង្កេតឃើញថា ការគោរពសិទ្ធិមានវត្តមាននៅពេលសវនាការមិនទាន់បានពេញលេញនៅឡើយទេ។ ជាលទ្ធផល មានសិទ្ធិចំនួន ៤ នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗត្រូវបានគោរពក្នុងចំណោមសិទ្ធិចំនួន ១១ ដែលត្រូវបានសង្កេតក្នុងឆ្នាំ២០២៣ គឺមានការធ្លាក់ចុះបន្តិចបើធៀបនឹងឆ្នាំ២០២២ មានសិទ្ធិចំនួន ៥ ត្រូវបានគោរព។

តាមរយៈការសង្កេត បានរកឃើញនូវកង្វះខាតគួរឱ្យកត់សម្គាល់មួយចំនួន ចំពោះការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌សំខាន់ៗ។ *ទីមួយ* សិទ្ធិមានសេរីភាពនៅតែត្រូវបានបន្តមិនទាន់គោរពបានពេញលេញដោយទិន្នន័យបង្ហាញថាមានការប្រើប្រាស់ការឃុំខ្លួនបណ្តោះអាសន្នច្រើន រួមទាំងសំណុំរឿងពាក់ព័ន្ធនឹងកុមារទំនាស់នឹងច្បាប់ផងដែរ។ ម.ស.ម.ក កត់សម្គាល់ថា មានជនជាប់ចោទប្រមាណ ៣ នាក់ក្នុងចំណោម ៤ នាក់បានទទួលរងនូវការប្រើប្រាស់វិធានការនៃការឃុំខ្លួនក្នុងឆ្នាំ២០២៣ ដែលមិនស្របទៅនឹងគោលការណ៍ថាការឃុំខ្លួនគឺសម្រាប់តែករណីពិសេសប៉ុណ្ណោះ។ *ទីពីរ* សិទ្ធិមិនត្រូវបានបង្ខិតបង្ខំឱ្យសារភាពអំពីពិរុទ្ធភាព ក៏ត្រូវបានចាត់ទុកថាមិនត្រូវបានគោរពពេញលេញដែរ។ បញ្ហានេះបណ្តាលមកពីមិនមានការស៊ើបអង្កេតឡើងវិញឱ្យបានហ្មត់ចត់ ក្នុងករណីដែលមានការលើកឡើងថាមានការប្រើហិង្សាក្នុងដំណាក់កាលស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដើម្បីបង្ខំឱ្យជនជាប់ចោទសារភាព។ *ទីបី* តុលាការទាំងនោះខកខានមិនបានផ្តល់ហេតុផលលម្អិត និងច្បាស់លាស់ក្នុងពេលប្រកាសនូវសេចក្តីសម្រេចរបស់ខ្លួនក្នុងសំណុំរឿងចំនួន ៤ ក្នុងចំណោម ៥ ដែលបានសង្កេត។ ដោយហេតុថាមានសវនាការចំនួន ៧ ក្នុងចំណោម ១០ មានរយៈពេល ៣០ នាទី ឬតិចជាងនេះ ទើបធ្វើឱ្យមានចម្ងល់ថាតើចៅក្រមអាចពិនិត្យមើលសំណុំរឿងទាំងនោះឱ្យបានហ្មត់ចត់កម្រិតណា។

ម.ស.ម.ក សង្ឃឹមថា ទិន្នន័យ ការវិភាគ និងអនុសាសន៍ ដែលបានលើកឡើងនៅក្នុងរបាយការណ៍នេះនឹងរួមចំណែកដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធយុត្តិធម៌ តាមរយៈការពង្រឹងនូវការប្រកាន់ភ្ជាប់នៃបទដ្ឋានស្តីពីការជំនុំជម្រះដោយយុត្តិធម៌ ព្រមទាំងគាំទ្រដល់អ្នកដែលធ្វើការដើម្បីធានាថាប្រព័ន្ធយុត្តិធម៌នៅកម្ពុជាមានភាពត្រឹមត្រូវ និងស្មើភាពសម្រាប់ទាំងអស់គ្នា។ លោកអ្នកអាចស្វែងរករបាយការណ៍នេះ នៅលើគេហទំព័ររបស់ ម.ស.ម.ក ជាភាសាខ្មែរ និងភាសាអង់គ្លេស និងទិន្នន័យអាចរកបាននៅលើប្រព័ន្ធផ្ទុកទិន្នន័យសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក ហ៊ុន ស៊ាងហាក់ អ្នកសម្របសម្រួលគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក តាមរយៈអ៊ីមែល seanghak.hun@cchrcambodia.org ឬលេខទូរស័ព្ទ +៨៥៥ (០) ១២ ៤០ ៣០ ៥០៕

– **ចប់** –

**បណ្ណាធិការ៖**

## អំពីគម្រោងសង្កេតការណ៍សវនាការ

គម្រោងសង្កេតការណ៍សវនាការនៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានចាប់តាំងពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌក្នុងតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តបទដ្ឋានជាតិ និងអន្តរជាតិនៃការជំនុំជម្រះដោយយុត្តិធម៌។ គម្រោងបានប្រើប្រាស់នូវរបកគំហើញដើម្បីលើកកម្ពស់ការយល់ដឹង និងចំណេះដឹងនៃគោលគំនិតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។ គោលបំណងរួមរបស់គម្រោងគឺ ធ្វើឱ្យមានភាពប្រសើរឡើងផ្នែកនីតិវិធី និងការអនុវត្តរបស់តុលាការកម្ពុជាដែលធានាថាមានការគោរពយ៉ាងពេញលេញនូវបទដ្ឋាននៃការជំនុំជម្រះដោយយុត្តិធម៌ក្នុងសវនាការព្រហ្មទណ្ឌ ព្រមទាំងបង្កើនការយល់ដឹង និងចំណេះដឹងនៃគោលគំនិតសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងចំណោមសាធារណជន។

សម្រាប់ព័ត៌មានបន្ថែម សូមមើលគេហទំព័រ ព្រមទាំងទិន្នន័យសង្កេតការណ៍សវនាការ។ ឯកសារផ្សេងៗទៀតពាក់ព័ន្ធនឹងគម្រោងអាចរកបាននៅទីនេះ។

## អំពីមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

ត្រូវបានបង្កើតនៅខែវិច្ឆិកា ឆ្នាំ២០០២ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅទូទាំងកម្ពុជា។ ម.ស.ម.ក គឺជាសមាជិកនៃដៃគូសន្ធនាអន្តជាតិដើម្បីសេរីភាពសម្តែងមតិ (IFEX) ជាបណ្តាញសកលលោកដើម្បីសេរីភាពសម្តែងមតិ និង CIVICUS៖ សម្ព័ន្ធពិភពលោកសម្រប់ការរួមរួមរបស់ពលរដ្ឋ។ ម.ស.ម.ក ក៏ជាសមាជិកអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិកនៃបណ្តាញប្រឆាំងនឹងទារុណកម្ម អែស អូ អែស និងជាសមាជិក OECD-Watch។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org បានទទួលពានរង្វាន់ពីមូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ ស្ថិតក្នុងប្រភេទ "សិទ្ធិ និងសេរីភាព" និងទទួលពានរង្វាន់ទំនាក់ទំនងសម្រាប់ការផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងផ្លាស់ប្តូរសង្គម នៅសាកលវិទ្យាល័យឃ្លីនឡែនក្នុងទីក្រុងប្រីសបែន (Brisbane)នៃប្រទេសអូស្ត្រាលី។